# មាតាបិតាក៏រាប់ផងដែរ

## ការជួយកូនរបស់លោកអ្នកនៅក្នុង - លំនាំ និងពិជគណិត (អក្សរលេខសាស្ត្រ)

លំនាំកើតមាននៅក្នុងគ្រប់ទាំងស្ថានការណ៍រៀងរាល់ថ្ងៃ។ ពិជគណិតគឺជាវិធីមួយគេប្រើជាតំណាងលំនាំមួយ។ ដើម្បីសំគាល់លំនាំណាមួយ កុមារត្រូវការឲ្យមានការដឹងយល់ថាតើគឺជាអ្វី។ នៅក្នុងគណិតសាស្ត្រពាក្យលំនាំគឺនិយាយអំពីលំនាំដែលកើតមានម្តងហើយម្តងទៀត។ នៅដើមឆ្នាំដំបូងនៃថ្នាក់បឋមសិក្សា កុមារនឹងរៀនសម្គាល់ដឹង ធ្វើ រៀបរាប់ ហើយបន្តលំនាំដែលកើតមានម្តងហើយម្តងទៀត។ គេនឹងត្រូវការសម្គាល់ដឹងអំពីចំនួននៃផ្នែក (ឬគោលគ្រឹះ) ប៉ុន្មានដែលបង្កើតទៅជាលំនាំ។ ជាដំបូង លំនាំទាំងនេះអាចបង្កើតចេញពីទ្រង់ទ្រាយ របស់ ឬរូបភាពមុននឹងធ្វើចេញទៅជាលំនាំមួយចំនួន។ ក្នុងកាលកុមារបន្តការសិក្សាផុតឆ្នាំបឋមសិក្សាហើយនោះ គេនឹងរៀនរកឃើញលេខដែលមើលមិនឃើញនៅក្នុងលំនាំ ហើយរុករកឃើញនូវទំនាក់ទំនងរវាងលេខបូក និងលេខដក ហើយនិងលេខគុណ និងលេខចែក។ គេនឹងចេះរៀបរាប់ផងដែរអំពីលំនាំចេញជាពាក្យ ហើយអាចកំណត់ក្បួនដើម្បីរៀបរាប់ពីលំនាំណាមួយ។ សិស្សនៅថ្នាក់មធ្យមសិក្សា នឹងរៀនចេះប្រើតួរអក្សរធ្វើជាតំណាងលេខ ហើយទទួលស្គាល់ថាតួរអក្សរអាចធ្វើជាតំណាងលេខនៃវត្ថុទាំងឡាយ។

ឧទាហរណ៍ ដំបូងសិស្សនឹងរៀនចេះពីទំនាក់ទំនងរវាងលេខដូចជា 3+4 = 4+3។ ដើម្បីរៀបរាប់ពីទំនាក់ទំនងទូទៅ 3 និង 4 អាចដាក់ជំនួយជាមួយតួរអក្សរ $a$ និង $b$ ដែលយើងអាចនិយាយថា $a+b = b+a$។

តួរអក្សរ $a$ និង $b$ ជាតំណាងលេខពីរណាមួយនៃរបស់ទាំងឡាយ។ ចំនួននៃរបស់ទាំងឡាយអាចផ្លាស់ប្តូរក៏ប៉ុន្តែទំនាក់ទំនងនៅជាដដែល។

## តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?

### ជាមួយកូនតូចៗរបស់លោកអ្នក:

- ពិភាក្សាអំពីលេខផ្ទះទាំងឡាយនៅតាមដងផ្លូវ ហើយប្រាប់ឲ្យកូនរបស់លោកអ្នករៀបរាប់ថាមានតើអ្វីកើតឡើងទៅនឹងលេខផ្ទះទាំងនោះ នៅពេលលោកអ្នកដើរតាមបណ្តោយដងផ្លូវ។
- សម្លឹងមើលគំរូនៃក្រដាសបិទជញ្ជាំង ហើយនិយាយអំពីលំនាំរបស់វា។ *តើមានផ្នែក ឬគោលគ្រឹះចំនួនប៉ុន្មាន ដែលបង្កើតចេញជាលំនាំ? តើលំនាំនោះចាប់ផ្តើមពីកន្លែងណា? តើលំនាំកើតមានម្តងហើយម្តងទៀតចំនួនប៉ុន្មានដង ពេញទូទាំងក្រដាសបិទជញ្ជាំង?*
- ឲ្យកូនរបស់លោកអ្នកធ្វើក្រដាសខ្ចប់ដែលមានលំនាំម្តងហើយម្តងទៀត បោះត្រាពេញលើក្រដាសខ្ចប់នោះ។
- លេងល្បែងកំសាន្តទាក់ទិននឹងសកម្មភាពរាងកាយដូចជាការទះដៃ និងការទន្រ្ទាំជើង។ ប្រាប់ឲ្យកូនរបស់លោកអ្នកធ្វើលំនាំនោះម្តងហើយម្តងទៀត រួចមកបង្កើតជាលំនាំមួយដើម្បីឲ្យលោកអ្នកធ្វើតាមម្តងហើយម្តងទៀត។
- ឲ្យកូនរបស់លោកអ្នកប្រើគ្រាប់អង្កាំ ឡេវ ឬដង្កៀបហាលខោអាវ ដើម្បធ្វើជាលំនាំមួយដែលមានម្តងហើយម្តងទៀត ហើយឲ្យគេនិយាយប្រាប់លោកអ្នកអំពីលំនាំនោះ។ លំនាំអាចមានជាពណ៌ ទំហំ រូបរាង ឬជារបស់ (ឧទាហរណ៍ ដង្កៀបហាលខោអាវ ដង្កៀបហាលខោអាវ ស្លាបព្រា ដង្កៀបហាលខោអាវ ដង្កៀបហាលខោអាវ ស្លាបព្រា)។ ប្រាប់ឲ្យកូនរបស់លោកអ្នករៀបរាប់អំពីលំនាំនោះ រួចហើយឲ្យគេនិយាយប្រាប់លោកអ្នកថាតើមានរបស់ចំនួនប៉ុន្មានដែលបង្កើតជាលំនាំ។


Curriculum K–12 Directorate, © NSW Department of Education

- ប្រើសម្ភារៈដដែលដោយតំរៀបជាព្រាវៗ រួចហើយប្រាប់ឲ្យកូនរបស់លោកអ្នកពន្យល់ប្រាប់លោកអ្នកថាតើវាជាលំនាំឬទេ។
- ប្រាប់ឲ្យកូនរបស់លោកអ្នកធ្វើលំនាំខុសៗគ្នាឲ្យបានច្រើន ដែលគេអាចធ្វើទៅបាន ចេញពីដង្កៀបហាលខោអាវពណ៌ខៀវបី ពណ៌សបី និងពណ៌ក្រហមបី។

**ជាមួយកូនធំៗ:**

- ជួយកូនរបស់លោកអ្នកបង្កើតគ្រឿងអលង្ការធ្វើពីគ្រាប់អង្កាំ។
- បង្រៀនកូនរបស់លោកអ្នកឲ្យចេះដេរប៉ាក់។ បន្ថយ ឬបង្កើនចំនួនថ្នេរមាននៅក្នុងលំនាំដេរប៉ាក់។
- គំពោងទេសភាព និងគំពោងផ្ទះ ជាទូទៅនឹងមានរួមទាំងគោលគ្រឹះនៃលំនាំ។ ឧទាហរណ៍ ទីធ្លារបង និងទីធ្លាក្រាលស៊ីម៉ង់ មានរួមទាំងលំដាប់នៃលំនាំនានា។ ប្រាប់ឲ្យកូនរបស់លោកអ្នករៀបរាប់អំពីលំនាំនោះ។



- រកមើលលំនាំទាំងឡាយមាននៅក្នុងលេខនៅក្នុងប្រតិទិនមួយ។ ហេតុអ្វីបានជាលំនាំទាំងនេះកើតមានឡើង?
- ពេលណាបើកបរឡាននៅក្នុងដំណើរឆ្ងាយ នាំគ្នាលេងល្បែងកំសាន្តនានាដើម្បីតាមដានរកមើលលំនាំទាំងឡាយដូចជា *សូមស្មានរកលេខរបស់ខ្ញុំ (x)* ។ ឧទាហរណ៍
    - *លេខរបស់ខ្ញុំ (x) គឺស្ថិតនៅក្នុងន្លោះលេខ 20 និងលេខ 5 វាជាលេខគូ ហើយជាលេខពហុគុណានឹង 3។*
- ពេលណាមើលល្បែងកីឡា ចូរនាំគ្នាគិតលេខពិន្ទុ ឬតាមដានមើលលំដាប់ពិន្ទុដែលនឹងអាចកើតមានឡើង។ ឧទាហរណ៍:
    - ក្រុមកីឡា Swans បានទទួលពិន្ទុទាត់ចូលទីចំនួន៤ដង ហើយពីក្រោយចំនួន៣ដង នៅក្នុងវគ្គ១ភាគ៤ដំបូង។ តើគេបានទទួលពិន្ទុប៉ុន្មាន?
    - ក្រុមកីឡា Bulldogs បានទទួលពិន្ទុទាត់ចូលទីចំនួន១២ នៅក្នុងវគ្គពាក់កណ្តាលទី១។ តើនឹងមានលំដាប់នៃការសាកល្បងទាត់ចូលទី និងការទាត់ចូលទី ណាខ្លះដែលនឹងផ្តល់នូវពិន្ទុនេះ?

